# គោលនយោបាយសង្ខេប

### *តើអ្វីទៅជាគោលនយោបាយសង្ខេប ?*

STREAM គោលនយោបាយសង្ខេប (PBs) រៀបចំឡើងក្នុងគោលបំណងរួមចំណែកនូវរាល់មេរៀនដ៏មានប្រយោជន៍ដែលទទួលបានតាមរយៈការងារស្រាវជ្រាវ និង អនុវត្តនៅតាមមូលដ្ឋាន។ វាគឺជាគោលនយោបាយខ្លីៗ ព្រមទាំងមានលក្ខណៈពិសេស។

គោលនយោបាយសង្ខេប រៀបចំឡើងសំដៅធ្វើយ៉ាងណាឱ្យមានការងាយស្រួលអាចអានបានលឿន រៀបរាប់នូវអត្ថបទសំខាន់ៗ និង បង្ហាញផ្លូវដល់អ្នកអានឱ្យយល់បានពីរបៀបស្វែងរកប្រធានបទប្រភពព័ត៌មានថ្មីៗបន្ថែមទៀត។ វាជួយសម្រួលដល់ប្រជាជនគ្រប់រូប ស្ថាប័ន និង អ្នកបង្កើតគោលនយោបាយ ដើម្បីប្រើប្រាស់វាធ្វើជាយន្តការ និង ឧបករណ៍ថ្មីៗសម្រាប់ជាជំនួយដល់ការគ្រប់គ្រងធនធានវារីជាតឱ្យបានត្រឹមត្រូវ និង លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ។

### *តើគោលនយោបាយសង្ខេបរៀបចំឡើងសម្រាប់នរណា ?*

គោលនយោបាយសង្ខេប គឺបង្កើតឡើងដើម្បីឱ្យអ្នកពាក់ព័ន្ធមួយចំនួនប្រើប្រាស់ ដូចជា :

- អ្នកបង្កើតគោលនយោបាយ
- អ្នកអនុវត្តគោលនយោបាយ
- អ្នករៀបចំសហគមន៍
- អង្គការក្រៅរដ្ឋាភិបាល
- ស្ថាប័នរដ្ឋាភិបាល
- ក្រុមអ្នកផ្តល់ជំនួយ
- ស្ថាប័នដ៏ទៃទៀតដែលយល់ថា គោលការណ៍អនុវត្តឱ្យកាន់តែប្រសើរ គឺមានប្រយោជន៍ដល់ពួកគាត់

### *តើនរណាជាអ្នកបង្កើត និង កែសម្រួលឱ្យវិតតែប្រសើរឡើងនូវគោលនយោបាយសង្ខេប ?*

គោលនយោបាយ អាចធ្វើការកែលំអដោយអ្នកដែលមានបទពិសោធន៍ ដើម្បីចែករំលែកនូវរាល់បទពិសោធន៍ទាំងអស់នោះដល់ (កសិករ និង អ្នកនេសាទ អ្នកពាក់ព័ន្ធនឹងសកម្មភាពនេសាទ ជំនាញការ)។ the STREAM Initiative ជាអ្នកសម្របសម្រួលគ្រប់ដំណើរការខាងលើ : ធ្វើការជាមួយដៃគូ កែសម្រួលការរៀបចំអត្ថបទ បកប្រែនូវរាល់អត្ថបទទាំងនោះចេញជាច្រើនភាសា និង ធ្វើការបែងចែកអត្ថបទទាំងនោះយ៉ាងទូលំទូលាយ។

រាល់សេរីនៃគោលនយោបាយសង្ខេប គឺរៀបចំឡើងដោយ ***"ការគាំទ្រដល់ការគ្រប់គ្រងប្រភពធនធានវារីជាតក្នុងតំបន់"*** **the Support to Regional Aquatic Resources Management (STREAM)** ដែលផ្តួចផ្តើមដោយបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មនៅអាស៊ីប៉ាស៊ីហ្វិច **(NACA)**។

### *តើខ្ញុំអាចរកបានគោលនយោបាយសង្ខេបនៅទីកន្លែងណា ?*

គោលនយោបាយសង្ខេប អាចស្វែងរកបានតាមរយៈមជ្ឈមណ្ឌលទំនាក់ទំនង (STREAM Communications Hubs) ទូទាំងអាស៊ី-ប៉ាស៊ីហ្វិក ជាភាសាជាតិ ឬពីការិយាល័យតំបន់របស់ STREAM នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៏ ឬតាមរយៈគេហទំព័រ : http://www.streaminitiative.org/Library/bpg/index.html

### *តើគោលនយោបាយសង្ខេបមានបរិយាយពីអ្វីខ្លះ ?*

គោលនយោបាយសងេបលេខ ១ *"ការកសាងមតិរួម"* បរិយាយពីបទពិសោធន៍របស់កសិករ អ្នកនេសាទ អាជ្ញាធរមូលដ្ឋាន សង្កាត់ ស្រុក រដ្ឋ និង រដ្ឋាភិបាលថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដោយរដ្ឋាភិបាលអង់គ្លេស DFID Natural Resources Systems Program project R ៨.១០០ " **គោលនយោបាយតាមដានកែលំអ ស្តីពី ការផ្តល់នូវសេវាកម្ម វារីវប្បកម្មដល់ប្រជាជនក្រីក្រ**" ដែលចាប់ផ្តើមអនុវត្តគម្រោងតាំងពីខែ មីនា ឆ្នាំ ២០០២ ដល់ខែ មេសា ឆ្នាំ ២០០៣ ដើម្បីស្វែងឱ្យឃើញ សាកល្បង និង ជម្រុញនូវរាល់យន្តការសម្រាប់នាំមកនូវសេវាកម្មជនបទឱ្យកាន់តែល្អប្រសើរដើម្បីអភិវឌ្ឍន៍ជីវភាពរស់នៅតាមជនបទ ជាមួយនឹងការស្វែងចេញឱ្យឃើញនូវគ្រប់សេវាកម្មទាំងអស់ក្នុងការជួយដល់វិស័យវារីវប្បកម្ម។

គោលនយោបាយសងេបលេខ ២ *"គោលដៅនៃការបង្កើនជីវភាពរស់នៅដោយពឹងផ្អែកលើវិស័យជលផល និង វិស័យវារីវប្បកម្ម"* បរិយាយពីបទពិសោធន៍ដែលទទួលបានពី **ជំនួយនៃគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់អង្គការ FAO** ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនការគ្រប់គ្រងធនធានវារីជាត នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិច ដោយចែករំលែកនូវរាល់ការយល់ដឹងពីលទ្ធផលនៃការវិភាគ និង ទិសដៅសម្រាប់បង្កើនជីវភាពរស់នៅ។